**NATIONS UNIES**
**HAUT COMMISSARIAT AUX DROITS DE L'HOMME**

**UNITED NATIONS**
**HIGH COMMISSIONER FOR HUMAN RIGHTS**

Téléfax: (41-22) -
Télégrammes:UNATIONS, GENEVE
Téléx: 41 29 62
Téléphone: (41-22) -
Internet www.ohchr.org
E-mail:

Address:
Palais des Nations
CH-1211 GENEVE 10

REFERENCE:

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦

## ឧត្តមស្នងការមានការព្រួយបារម្ភចំពោះការទិទៀនអំពីការងារសិទ្ធិមនុស្សនៅកម្ពុជា

លោកស្រី **លួីស អាប៊ួរ** ឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស បានសំដែងការព្រួយបារម្ភ នៅថ្ងៃនេះ ចំពោះការអត្ថាធិប្បាយដែលបានថ្លែងដោយនាយករដ្ឋមន្ត្រីកម្ពុជា នៅក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ ពាក់ព័ន្ធនឹងការងារសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេស ។

លោកស្រីឧត្តមស្នងការនិយាយសំដៅដល់របាយការណ៍នានាដែលថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើការទិទៀនលោក **យ៉ាសហ៍ ហ្គាយ** តំណាងពិសេសនៃលោកអគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងការិយាល័យរបស់លោកស្រីនៅក្នុងប្រទេសនេះ ។

លោកស្រី **លួីស អាប៊ួរ** បានមានប្រសាសន៍ថា "នៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅ លោកតំណាងពិសេសគ្រប់រូប និងបុគ្គលិកការិយាល័យខ្ញុំនៅកម្ពុជា ដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣ ហើយដែលសហគមន៍អន្តរជាតិបានកំណត់អាណត្តិឱ្យការិយាល័យនេះដើម្បីឃ្លាំមើលការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និងសហការជាមួយរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីធានាថាបទដ្ឋាននានាដែលរដ្ឋាភិបាលទទួលយកត្រូវបានគោរព" ។

លោកស្រីមានប្រសាសន៍ថា "ខ្ញុំជឿជាក់ថាពួកគេនឹងបន្តទទួលបាននូវកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងពីរដ្ឋាភិបាល" ។

**ហូសេ លួីស ឌាយ៉ាស**
មន្ត្រីផ្នែកព័ត៌មាន និងជាអ្នកនាំពាក្យ
ការិយាល័យឧត្តមស្នង ការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស
ទូរស័ព្ទលេខ : ៤១២២ ៩១៧ ៩២៤២
ទូរសារលេខ : ៤១២២ ៩១៧ ៩០០៤
អ៊ីម៉េល : jdiaz@ohchr.org